


| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| ១. ការបន្តចាប់ដីបំពានច្បាប់ (Continued Land Grabs, p. 1) | … ១ |
| ២. អាងអំណាចធ្វើបាបរាស្ត្រ ? (Power Abuse, p. 2) | … ៣ |

## ការបន្តចាប់ដីបំពានច្បាប់

ក្រោយពីមានការជួសជុលផ្លូវជាតិលេខ១៩ កាលពីបីឆ្នាំកន្លងទៅ ខេត្តមណ្ឌលគិរី ដែលហាក់បីដូចជាខេត្តជនបទដាច់ស្រយាលមួយរបស់កម្ពុជាក្នុងអំឡុងទសវត្សរ៍៨០និង៩០ ត្រូវបានទទួលនូវការផ្លាស់ប្តូរ និង ការអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ។ ការផ្លាស់ប្តូរ និង ការអភិវឌ្ឍន៍មួយចំនួន បានធ្វើឱ្យអាជ្ញាធរមូលដ្ឋាន និង ស្ថាប័នអភិវឌ្ឍន៍មានការព្រួយបារម្ភ និង ពិបាកគ្រប់គ្រងជាទីបំផុត ។ អាកាសធាតុ សម្រស់ធម្មជាតិ និង ប្រពៃណីជនជាតិភាគតិចនៃខេត្តមណ្ឌលគិរី បានទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិឱ្យទៅកាន់ខេត្តនេះកាន់តែច្រើនឡើងៗរៀងរាល់សប្តាហ៍ ។

ការផ្លាស់ប្តូរ និង ការអភិវឌ្ឍន៍ទាំងនេះបានធ្វើឱ្យមានការរានចាប់យកដីមិនឈប់ឈរ ។ ជនជាតិភាគតិច ដែលជាជនជាតិដើម កំពុងស្ថិតក្នុងសភាពក្រីក្រតោកយ៉ាក និង ខ្វះខាតស្បៀងអាហារត្រូវបានបង្ខំចិត្តបញ្ចាំ-លក់ដី ដើម្បីប្តូរយកអង្ករសម្រាប់ហូបចុក ក្នុងតម្លៃថោកជាទីបំផុត ។ និន្នាការនេះបានធ្វើឱ្យគ្រួសារជនជាតិភាគតិចមួយចំនួនត្រូវបាត់បង់ដីធ្លី និង មានទំនាស់ជាមួយសមាជិកសហគមន៍របស់គាត់ទៀតផង ។ ប្រជាជនខ្លះត្រូវទៅរានដីថ្មីក្រោយពីបញ្ចាំ-លក់ដីរបស់ខ្លួន ។

ប្រជាជនក្រៅសហគមន៍ ដែលជាអ្នកមានទ្រព្យសម្បត្តិ ឬអ្នកមានអំណាចខ្លះ បានឃុបឃិតជាមួយសមាជិកអាជ្ញាធរមូលដ្ឋានខិលខូច ដោយគ្រាន់តែចំណាយប្រាក់បន្តិចបន្តួច ដើម្បីព័ទ្ធយកភ្នំមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ ខ្លះទៀតដុតព្រៃកាប់រំលំឈើ ដុតចំការកូនស្រល់ ដែលជាកម្មសិទ្ធិ

របស់ជាតិ ហើយព័ទ្ធរបងយកដីមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយមិនគោរពច្បាប់ និង មិនទាំងស្តាប់នូវការព្រមានរបស់អាជ្ញាធរមូលដ្ឋានទៀតផង ។

បច្ចុប្បន្ន នៅតាមដងផ្លូវគ្រប់ទីកន្លែង ដីសុទ្ធតែមានបោះបង្គោល-ព័ទ្ធរបង ហើយដីភាគច្រើនសុទ្ធតែមានទំហំធំៗគួរឱ្យចាប់អារម្មណ៍ និង ព្រួយបារម្ភ ។ ថ្មីៗនេះនៅក្នុងអង្គសិក្ខាសាលាមួយ អាជ្ញាខេត្ត បានព្រមានផង សំណូមពរផង និង គម្រាមផង ឱ្យមានការបញ្ឈប់ជាបន្ទាន់នូវការរំលោភយកដីរបស់រដ្ឋ និង ដីប្រជាជនមូលដ្ឋាន ។ ប៉ុន្តែជនល្មើសហាក់ដូចជាធ្វើព្រងើយមិនអើពើ ។ ក្នុងករណីខ្លះដីរបស់ពួកគេមានទំហំធំៗ ស្ទើរតែវាស់ពុំបាន ។ អ្នកខ្លះ យកព្រំដែនប្រទេសវៀតណាមធ្វើជាគោលសម្គាល់ព្រំដីរបស់ខ្លួន អ្នកខ្លះយកមាត់អូរធ្វើជាព្រំដីរបស់ខ្លួន អ្នកខ្លះមានព្រំដីចំងាយមួយភ្លើងឆេះព្រៃរលត់ ហើយអ្នកខ្លះមានព្រុំដីចំងាយមួយគ្រាប់កាំភ្លើង ។ បើមិនមានការទប់ស្កាត់ឱ្យបានទាន់ពេលវេលា និង មានប្រសិទ្ធភាពទេនោះ ដីព្រៃ និង ជម្រកសត្វព្រៃពិតជាខ្ទិចខ្ទាំ រីឯជនជាតិភ្នងប្រកដជាកាន់តែ ក្រទុរគតរកអង្ករច្រកឆ្នាំងក៏មិនបាន ។

**Continued Land Grabs**

After the rehabilitation of National Road 14, Mondulkiri province which was nearly isolated during the 1980s and 1990s has now been changed and developed. International and national tourists are attracted by its weather, natural beauty and culture of the Phnong indigenous communities. However, certain changes and development have caused great concerns to both local authorities and development agencies.

The Phnong indigenous communities live in poverty and are faced with shortage of food almost every year. To address their immediate needs many have pawned and/or sold out their land at very cheap price and have moved to get new land. In some cases, they get into conflict with their fellow community members.

Some rich and powerful people have colluded with certain members of local authorities to take mountains into their possessions. Some cut standing trees and/or set fire on young pine plantations and then claim the land, which in fact belongs to the state. They never bother about the law and local authorities' warnings. Some of them take into their possessions sizable land, sometimes, without clear demarcation. Some take Vietnamese border as the border of their land, some take natural streams as the border of their land, some consider the edge of forest fire as the border of their land and some consider the border of their land just the race of the bullets. If this continues and no immediate and effective actions are taken forestland and wildlife habitats will disappear, and life of Phnong indigenous communities will be always in misery.

## អាងអំណាចធ្វើបាបរាស្ត្រ

កាលពីដើមខែធ្នូ ឆ្នាំ២០០៤ បុរស ម.ភ ដែលគេជឿថាជាមេបញ្ជាការវិរៈលេខ២០៤ ឈរជើងនៅស្រុកស្នួល ខេត្តក្រចេះ បានគំរាមកំហែង និង បង្ករបួសស្នាមដល់ប្រជាសហគមន៍ការពារព្រៃឈើ និង ធនធានធម្មជាតិពីរនាក់ដោយអាងអំណាចរបស់ខ្លួនជាទាហាន ។ បុរស ម.ភ បានប្រើប្រាស់កូនទាហានរបស់

ខ្លួនចំនួន៩នាក់ ឱ្យធ្វើការវាយដំលោក អេង អាន ជាប្រជាសហគមន៍នៅភូមិថ្មហាលវាល ឃុំ២ធ្នូ ស្រុកស្នួល និង លោក ម៉ាន់ ឃីន ជាប្រជាសហគមន៍ភូមិត្រពាំងស្រែក្នុង ឃុំ២ធ្នូ ស្រុកស្នួល ឱ្យមានរបួសលើស្មាឆ្វេង ផ្ទៃមុខ និង ខ្នង ។ ការប្រព្រឹត្តិបែបនេះ មានសភាពប្រហាក់ប្រហែលនឹងកងសន្តិសុខខ្មែរក្រហម ។ ហេតុអ្វីបានជាយោធាដែលមានឈាមជ័រជាខ្មែរ រស់នៅដោយសារការគាំទ្ររបស់ខ្មែរ ជាកូនខ្មែរ មានភារៈកិច្ចការពារជាតិខ្មែរ បែរជាមកធ្វើបាបប្រជាជនខ្មែរទៅវិញ? ហូបបាយរាស្ត្រ តែធ្វើបាបរាស្ត្រ! តើនេះជាភាពអយុត្តិធម៌ ឬភាពល្ងង់ខ្លៅមិនចេះច្បាប់ ឬភាពឃោរឃៅរបស់ទាហាន ? តើនរណាអាចទប់ស្កាត់អំពើទាំងនេះបាន ? តើនរណាខុស និង រងគ្រោះ ?

នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០០៤ នៅពេលដែលប្រជាសហគមន៍បានធ្វើការល្បាតការពារព្រៃឈើនៅក្នុងមូលដ្ឋានរបស់ពួកគាត់ ក៏បានជួបប្រទះនឹងការដឹកជញ្ជូនឈើខុសច្បាប់ ដោយគ្មានការអនុញ្ញាតិមួយបានកើតមានឡើង ។ ការដឹកជញ្ជូនឈើនេះ បានធ្វើឡើងតាមគោយន្តដោយឈ្មោះ មិន សុខុន ។ មិន សុខុន ជាម្ចាស់គោយន្ត ហើយក៏ជាប្រជាជនមូលដ្ឋានដែរ ។ បុគ្គលនេះបានដឹកជញ្ជូនឈើសរសរទំហំ ១៥ស.ម x ១៥ស.ម x ៣០០ស.ម ចំនួន ១៨ ដើម និង ក្តារ ៦ស.ម x ២០ស.ម x ៣០០ស.ម ចំនួន ៧

**Power Abuse**

While patrolling their local forests on 6 December 2004, community members came across a transportation of logs and lumbers by a walking tractor by Min Sokhon. The transportation was stopped and investigated. The community members found out that the activity was illegal, and then reported immediately to local forest administration and local authorities, including police.

Min Sokhon convinced local forest administration, district authorities and community members that he needed the woods for constructing his own house. All concerned allowed him to take the woods, but required that he made agreement with communities that the woods were only for the construction of his house, but not for anything else.

He was suspected. The communities then assigned two of their members to monitor and trace the wood transportation of Min Sokhon. The two community members, Mr. Eng Ann and Mr. Mann Khin, found out the truth. Min Sokhon, instead of taking the woods for the construction of his house, transported them to a local wood processing mill located behind the base of the Army Division No. 204 assumingly under the command of Mr. M.P.

During their mission the two community members did not do anything to Min Sokhon or Mr. M.P. They planned to return to the villages to report to their communities. Unfortunately, their motor-bike had a flat tire just in front of the army base. They stopped at the motor-bike repair shop nearby to fix the flat tire.

Mr. M.P and his soldiers went out of their barrack, and beat the two community persons and dragged them into their barrack. The communities, when heard of the situation, gathered and protested. Mr. M.P, informed of the communities' reaction, released the two persons and sent them to the district office to wash his hands off his atrocity.

Communities' courage, effort and solidarity to protect natural resources should be strongly supported and encouraged. They must not be left to be threatened and punished. This cannot be achieved, however, until the rule of law prevails.

សន្តិក ។ ឃើញដូច្នេះ ប្រជាសហគមន៍ដែលកំពុងដើរល្បាតការពារព្រៃក៏បានឃាត់ឈ្មោះមិន សុខុន ដើម្បីសាកសួរ ។ ក្រោយពីដឹងថា ឈ្មោះនេះពុំមានការអនុញ្ញាតិត្រឹមត្រូវតាមច្បាប់សំរាប់ការកាប់ និង ដឹកជញ្ជូនឈើ ប្រជាសហគមន៍ក៏បានរាយការណ៍ជូនរដ្ឋបាលព្រៃឈើ និង អាជ្ញាធរស្រុកជាបន្ទាន់ ។

នៅពេលបានជួបជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន និង អាជ្ញាធរស្រុក ឈ្មោះមិន សុខុន បានដោះសារថាឈើទាំងអស់ គឺសម្រាប់សង់លំនៅដ្ឋានរបស់ខ្លួន ។ អាជ្ញធរ ស្ថាប័នទទួលខុសត្រូវ និង ប្រជាសហគមន៍ក៏យល់ព្រមឱ្យគាត់ដឹកឈើទាំងនោះចេញពីព្រៃសម្រាប់យកទៅធ្វើផ្ទះ របស់គាត់នៅភូមិត្រពាំងស្រែក្នុង និង ឱ្យធ្វើកិច្ចសន្យាជាមួយសហគមន៍ ។

ដោយប្រជាសហគមន៍សង្ស័យថាឈ្មោះ មិន សុខុន បែបទំនងជាភូតកុហក ពួកគាត់ក៏ចាត់ឱ្យលោក អេង អាន និង លោក ម៉ាន់ ឃីន ធ្វើការឃ្លាំមើលការដឹកជញ្ជូនឈើរបស់ឈ្មោះ មិន សុខុននេះ ដើម្បីឱ្យបានច្បាស់ថាគាត់ពិតជាដឹកយកទៅសាងសង់ផ្ទះរបស់គាត់ពិតមែន ។ ពេលតាមដានទៅ ក៏បានឃើញថាបុគ្គលឈ្មោះ មិន សុខុននេះ ពុំបានដឹកឈើទាំងនោះយកទៅភូមិសម្រាប់សាងសង់លំនៅដ្ឋានរបស់ខ្លួនដូចបានសន្យានោះឡើយ ។ គាត់បែរជាដឹកឈើទាំងនោះយកទៅឱ្យរោងម៉ាស៊ីនកែច្នៃឈើមួយកន្លែង នៅក្រោយបន្ទាយទាហានក្នុងមូលដ្ឋានស្រុកស្នួល ដែលគ្រប់គ្រងដោយបុរស ម.ភ ។ នៅពេលឃ្លាំមើលសកម្មភាពទាំងនេះ ប្រជាសហគមន៍ទាំងពីរនាក់ពុំមានធ្វើសកម្មភាពអ្វីឱ្យប៉ះពាល់ដល់បុរស ម.ភ និង អ្នកដឹកឈើនោះឡើយ ។

ក្រោយពីបានស្វែងយល់ការពិតរួចហើយ ប្រជាសហគមន៍ទាំងពីរនាក់បានធ្វើដំណើរវិលត្រឡប់ទៅកាន់ភូមិរបស់ពួកគាត់វិញដើម្បីជូនដំណឹងទៅឱ្យសហគមន៍របស់ពួកគាត់ ។ ប៉ុន្តែជាថៃជន្យ ម៉ូតូរបស់ពួកគាត់ត្រូវបែកកង់នៅត្រង់មុខបន្ទាយទាហាននោះ ។ ពួកគាត់ក៏ឈប់សម្រាកដើម្បីឱ្យជាងប៉ះកង់ម៉ូតូ នៅក្បែរបន្ទាយទាហាននោះ ។ ស្រាប់តែនៅម៉ោងប្រហែល ៣ម៉៣០នាទី បុរស ម.ភ និង កូនទាហាន៩នាក់បានចេញពីបន្ទាយរបស់ខ្លួនមកធ្វើការវាយដំសមាជិកសហគមន៍ទាំងពីរនាក់យ៉ាងដំណំ ហើយក៏ចាប់អូសយកពួកគាត់ចូលទៅក្នុងបន្ទាយ ។ ដំណឹងអកុសលនេះក៏បានបញ្ជូនទៅដល់សហគមន៍ ។ ពេលនោះសហគមន៍ក៏បានកេណ្ឌសមាជិករបស់ពួកគាត់មកតវ៉ាដើម្បីរំដោះយកសមាជិកគាត់ទាំងពីរនាក់ត្រឡប់ទៅភូមិវិញ ។ បុរស ម.ភ ដោយខ្លួនជាទាហានមានបណ្តាញក្នុងមូលដ្ឋាន ក្តាប់សភាពការណ៍នេះបាន ក៏រូតរះបញ្ជូនសមាជិកសហគមន៍ទាំងពីរនាក់ឱ្យទៅអាជ្ញាធរស្រុករួចជាស្រេច ដើម្បីសំអាតខ្លួន ។

ប្រសិនបើ ប្រជាសហគមន៍មិនបានទទួលដំណឹងអំពីសមាជិករបស់ខ្លួនដែលរងគ្រោះឱ្យទាន់ពេលវេលា ហើយប្រសិនបើពួកគាត់មិនរួមសាមគ្គីគ្នាទេនោះ មិនដឹងថាវាសនាសមាជិកសហគមន៍ទាំងពីរនាក់របស់ពួកគាត់ទៅជាយ៉ាងណាឡើយ ។ សេចក្តីក្លាហាន សាមគ្គីភាព និង ការខិតខំប្រឹងប្រែង របស់សហគមន៍ គួរតែទទួលបាននូវការជ្រោមជ្រែងគាំទ្រ និង លើកទឹកចិត្ត មិនគួរបណ្តោយឱ្យពួកខិលខូចដូចជាបុរស ម.ភ គម្រាមកំហែង ធ្វើបាបឡើយ ។ បុរស ម.ភ ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដើម្បីធ្វើបែបនេះទៅបានលុះត្រាតែមាននិតិរដ្ឋ ។



Non-wood product of the forest